# តើលោកអ្នកកំពុងទទួលប្រាក់សោធន និងកំពុងធ្វើការឬទេ?



We speak your language ☎ 13 1202

*Are you receiving a pension and working?* – **Khmer**

ដើម្បីគណនាចំនួនប្រាក់សោធនដែលយើងខ្ញុំអាចបើកជូនលោកអ្នក យើងខ្ញុំត្រូវដឹងពេលដែលស្ថានការណ៍លោកអ្នកផ្លាស់ប្តូរ។

សូមចងចាំក្នុងការ:

- ប្រាប់យើងខ្ញុំ បើលោកអ្នកឬគូរួមមេត្រីភាពរបស់លោកអ្នក ចាប់ផ្តើមឬឈប់ធ្វើការ
- ប្រាប់យើងខ្ញុំអំពី**ប្រាក់ចំណូលមិនទាន់បង់ពន្ធ**របស់លោកអ្នក។ នេះគឺជាចំនួនប្រាក់មុនបង់ពន្ធនិងចំនួនកាត់យកចេញផ្សេងៗទៀត។
- ប្រាប់យើងខ្ញុំ បើចំនួនម៉ោងធ្វើការរបស់លោកអ្នកផ្លាស់ប្តូរ
- ប្រាប់យើងខ្ញុំក្នុងរង្វង់ពេល 14 ថ្ងៃ បើប្រាក់ចំណូលរបស់លោកអ្នកកើនឡើង
- ប្រាប់យើងខ្ញុំភ្លាម បើប្រាក់ចំណូលរបស់លោកអ្នកធ្លាក់ចុះ។ លោកអ្នកអាចមានសិទ្ធិទទួលប្រាក់សោធនថែមទៀត
- សុំឲ្យនិយោជកប្រាប់នូវអត្រាប្រាក់បើកប្រចាំម៉ោងរបស់លោកអ្នក ដោយមានរួមទាំងអត្រាប្រាក់បើកនៅថ្ងៃចុងអាទិត្យឬថ្ងៃឈប់សំរាក ឬអត្រាប្រាក់បើកសំរាប់ពេលលើសម៉ោងធ្វើការ ព្រមទាំងប្រាក់ឧបត្ថម្ភណាមួយដែលលោកអ្នកទទួល
- ផ្តល់ឲ្យយើងខ្ញុំនូវប័ណ្ណជូនដំណឹងអំពីប្រាក់ចំណូលរបស់លោកអ្នក **ហើយនិង**
- ប្រាប់យើងខ្ញុំនូវប្រាក់ចំណូលដែលទទួលពីនិយោជកនីមួយៗ បើលោកអ្នកឬគូរួមមេត្រីភាពរបស់លោកអ្នកមាននិយោជកច្រើនជាងម្នាក់។

បើលោកអ្នកឬគូរួមមេត្រីភាពរបស់លោកអ្នក មិនប្រាប់យើងខ្ញុំអំពីការផ្លាស់ប្តូរណាមួយដូចដែលតម្រូវឲ្យធ្វើឡើងទេនោះ វាអាចបណ្តាលឲ្យ:

- យើងខ្ញុំបញ្ឈប់ឬពន្យារពេលបើកប្រាក់បំណាច់របស់លោកអ្នក **ហើយ/ឬ**
- លោកអ្នកអាចត្រូវបង់សងមកវិញនូវចំនួនប្រាក់បើកលើស **ហើយ/ឬ**
- លោកអ្នកត្រូវបង់ថ្លៃឈ្នួលសំរាប់ការទារសំណងប្រាក់លើសមកវិញ នៅក្នុងករណីខ្លះ។

ដើម្បីនិយាយទៅកាន់ Centrelink ជាភាសាខ្មែរ សូមទូរស័ព្ទទៅលេខ **13 1202*** ។
លោកអ្នកក៏អាចរកឃើញព័ត៌មានជាភាសាលោកអ្នក នៅតាមវ៉ិបសៃ **www.centrelink.gov.au** ផងដែរ។

** លោកអ្នកអាចប្រើកិច្ចបំរើទូរស័ព្ទស្តង់ដារនៅគ្រប់ទីកន្លែងទាំងអស់ក្នុងរង្វង់ប្រទេសអូស្ត្រាលីដើម្បីទូរស័ព្ទទៅកាន់លេខចាប់ផ្តើមដោយលេខ “13” ដោយបង់ថ្លៃមិនលើសពីថ្លៃទូរស័ព្ទក្នុងតំបន់ឡើយ (ថ្លៃទូរស័ព្ទអាចមានតម្លៃខុសៗគ្នា ដោយអាស្រ័យលើក្រុមហ៊ុនផ្តល់កិច្ចបំរើទូរស័ព្ទ)។ ទូរស័ព្ទទៅលេខចាប់ផ្តើមដោយលេខ “1800” ឥតមានគិតថ្លៃទេ។ ទូរស័ព្ទចេញពីទូរស័ព្ទសាធារណៈដែលត្រូវបង់ប្រាក់ ទូរស័ព្ទចល័ត និងត្រូវបង់ថ្លៃតាមអត្រាខ្ពស់ជាងនោះ។*